# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្តីប្រចាំខែមីនា



លេខ ២៥៧ ឆ្នាំទី២២
ពុទ្ធសករាជ ២៥៦៥ គ្រិស្តសករាជ ២០២២

Issue 257 Volume 22
Before Christ 2565 Common Era 2022

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចវិបុលសេនាភក្តីប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ........................ ១
- ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភាសំណេះសំណាលថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ រាជធានីភ្នំពេញ........................ ៣
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........................ ៦


## សកម្មភាពគណៈកម្មការ




- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលក្រុមប្រឹក្សាឃុំក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ........................ ៨
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលក្រុមប្រឹក្សាឃុំក្នុងស្រុកមេមត់ ស្រុកពញាក្រែក និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ........................ ១០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលអាជ្ញាធរឃុំ ក្នុងស្រុកស្វាយលើ និងស្រុកសូទ្រនិគម ខេត្តសៀមរាប........................ ១២
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តកំពត និងខេត្តកែប........................ ១៤
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាឃុំ ក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី........................ ១៦
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........................ ១៨
- ការងារទទួលពាក្យបណ្តឹង........................ ២០
- សមាជិក សមាជិកាព្រឹទ្ធសភាចុះបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨........................ ២១
- សមាជិក សមាជិកាព្រឹទ្ធសភាអញ្ជើញបំពេញបេសកកម្មក្រៅប្រទេស ........................ ៣២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................ ៣៣


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងកំណត់ទិសដៅការងារខែមីនា ឆ្នាំ២០២២........................ ៣៧
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញបិទវគ្គបច្ចេកទេសក្នុងការតាក់តែងឯកសារសម្រាប់គាំទ្រមហាសន្និបាតអាយ៉ាលើកទី៤៣........................ ៣៩
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញបំពេញបេសកកម្មការងារនៅប្រទេសបារាំង........................ ៤១
- ឯកឧត្តម អ៊ុំ សារឹទ្ធ ចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង........ ៤២
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........................ ៤៣



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខធី

លោក ទេព មករា

លោក កុក រ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

កញ្ញា សុខ សុជាតា


ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យឯកឧត្តម បូរកែវ ភូមិវង្សសៃ ឯកអគ្គ-រដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវតែងតាំងថ្មី ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា។

ក្របក្រោយ ៖ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ប្រធានស្តីទីព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយនឹងថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ៕


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855 23)211441, 211442, 211443,ទូរសារ: (855 23)211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# សម្តេចវិបុលសេនាភក្តីប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



*ឯកឧត្តម បួរកែវ ភូមិវង្សសៃ ប្រគល់សារតាំងជូនសម្តេចប្រមុខរដ្ឋស្តីទី*

នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៩:00 នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **បួរកែវ ភូមិវង្សសៃ** (Buakeo PHUMVONGSAY) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅចំពោះឯកឧត្តម **បួរកែវ ភូមិវង្សសៃ** ដែលត្រូវបានឯកឧត្តមប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះ ឯកឧត្តម **បួរកែវ ភូមិវង្សសៃ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រមុខរដ្ឋស្តីទី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អនុញ្ញាតឱ្យឯកឧត្តមបានចូលជូនសារតាំង និងសម្តែងការគួរសម ហើយឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានពាំនាំនូវការសួរសុខទុក្ខពីសំណាក់ឯកឧត្តមប្រធានរដ្ឋ និងថ្នាក់ដឹកនាំកំពូល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងជូនចំពោះសម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំកំពូលនៃព្រះរាជាណាចក្រកម្ពុជា។

ព្រមជាមួយគ្នានោះ ឯកឧត្តមឯកអគ្គរដ្ឋទូតបានពាំនាំពីឯកឧត្តមប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នូវការក្រាបបង្គំយាងព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បំពេញព្រះរាជទស្សនកិច្ចជាផ្លូវរដ្ឋនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ





*ទិដ្ឋភាពក្នុងទស្សនាវត្ថុអនុស្សាវរីយ៍*



*ទិដ្ឋភាពក្នុងជំនួបសវនាការ*

នៅពេលវេលាសមស្របណាមួយ។

ឯកឧត្ដម **ប៊ូរកែវ ភូមិវង្សសៃ** បានសម្ដែងនូវសេចក្ដីរីករាយចំពោះទំនាក់ទំនង សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងរដ្ឋាភិបាល និងប្រជាជននៃប្រទេសទាំងពីរ។ ឯកឧត្ដមបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព និងការរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្ដម **ប៊ូរកែវ ភូមិវង្សសៃ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាដែលបានជួយឧបត្ថម្ភគាំទ្រដល់ប្រទេសឡាវនាពេលកន្លងទៅ ជាពិសេសការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ វ៉ាក់សាំង រថយន្តដឹកវ៉ាក់សាំង និងឧបករណ៍វេជ្ជសាស្ត្រមួយចំនួន។ ឯកឧត្ដមបានបញ្ជាក់ថា ប្រទេសឡាវសូមគាំទ្រចំពោះតួនាទីរបស់ប្រទេសកម្ពុជាជាប្រធានអាស៊ាន។

សម្ដេចប្រមុខរដ្ឋស្ដីទីមានសេចក្ដីសោមនស្សរីករាយ និងពេញចិត្តជាខ្លាំងដោយបានមើលឃើញចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ មានការរីកចម្រើនជាបន្តបន្ទាប់ឥតឈប់ឈរលើគ្រប់វិស័យ ហើយទំនាក់ទំនងនេះត្រូវបានលើកកម្ពស់ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង។

សម្ដេចវិបុលសេនាភក្ដីប្រមុខរដ្ឋស្ដីទីមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្ដមជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមនឹងខិតខំពង្រឹងពង្រីកនូវចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ ស៊ីជម្រៅបន្ថែមទៀតលើបញ្ហានយោបាយ សន្តិសុខ ការពារជាតិ អប់រំ សុខាភិបាល និងខិតខំជំរុញឱ្យមានការផ្លាស់ប្ដូរពាណិជ្ជកម្ម សេដ្ឋកិច្ច វិនិយោគ ទេសចរណ៍ វប្បធម៌ និងការផ្លាស់ប្ដូររវាងប្រជាជននិងប្រជាជនឱ្យកាន់តែទូលំទូលាយ ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រទេស និងប្រជាជនទាំងពីរ។

សម្ដេចវិបុលសេនាភក្ដីប្រមុខរដ្ឋស្ដីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រៀមខ្លួនជានិច្ចដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្ដមឯកអគ្គរដ្ឋទូត ក៏ដូចជាស្ថានទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីនាំមកនូវផលប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរទៅវិញទៅមក។

តាមរយៈឯកឧត្ដមឯកអគ្គរដ្ឋទូត សម្ដេចវិបុលសេនាភក្ដីប្រមុខរដ្ឋស្ដីទីបានផ្ដាំផ្ញើនូវព្រះរាជបណ្ដាំសួរសុខទុក្ខដោយសេចក្ដីគោរព និងសេចក្ដីនឹករលឹកពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្ដម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិនៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្ដមប្រធានរដ្ឋ និងថ្នាក់ដឹកនាំជាន់ខ្ពស់គ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

សម្ដេចវិបុលសេនាភក្ដីប្រមុខរដ្ឋស្ដីទីបានប្រសិទ្ធពរជូនឯកឧត្ដមឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្ដុង្គឧត្ដម៕

(អត្ថបទ៖ ទេព មករា រូបភាព៖ គង់ យ៉ារីន)

# ឯកឧត្តមប្រធានស្ដីទីព្រឹទ្ធសភាសំណេះសំណាល ថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ រាជធានីភ្នំពេញ




*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌកំបូល*

នាព្រឹកថ្ងៃទី៤ ទី៩ ទី១១ ទី១៥ ទី១៦ និងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាល ថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ ក្នុងខណ្ឌកំបូល ខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ ខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមនៅក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ និងការងារត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ។

ក្នុងឱកាសចុះជួបសំណេះសំណាលដាច់ដោយឡែកពីគ្នាតាមខណ្ឌនីមួយៗ ប្រធានក្រុមប្រឹក្សាខណ្ឌបានធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលការងារជាវិជ្ជមាន និងបញ្ហាប្រឈមមួយចំនួនជូនអង្គពិធី។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដ៏ល្អប្រសើរក្នុងការអនុវត្តការងារប្រចាំថ្ងៃ ការគ្រប់គ្រងប្រជា-




*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌព្រែកព្នៅ*



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌច្បារអំពៅ*

ពលរដ្ឋនៅទូទាំងខណ្ឌ ដើម្បីឱ្យមូលដ្ឋានមានការអភិវឌ្ឍ និងការរីកចម្រើនលើកគ្រប់វិស័យ។ ទន្ទឹមនឹងនោះ ដើម្បីបម្រើសេវាជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត សូមថ្នាក់ដឹកនាំខណ្ឌ ក៏ដូចជាមន្ត្រីជំនាញ នៃរដ្ឋបាលខណ្ឌ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការបំពេញការងារតាមភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់ និងប្រតិបត្តិឱ្យបានត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ ព្រមទាំងបន្តយកចិត្តទុកដាក់ចំពោះការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដែលគ្រប់អាយុមានសិទ្ធិបោះឆ្នោត មិនទាន់មានឯកសារគ្រប់គ្រាន់ បាត់ ឬឯកសារខូច ឯកសារហួសសុពលភាពប្រើប្រាស់ សូមណែនាំឱ្យដាក់ពាក្យស្នើសុំធ្វើឯកសារថ្មី ដែលជាឯកសារពាក់ព័ន្ធនឹងច្បាប់បោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីទទួលបានសិទ្ធិគ្រប់គ្រាន់សម្រាប់ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលថ្នាក់ដឹកនាំខណ្ឌ ក្រុមប្រឹក្សាសង្កាត់*






*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌ៧មករា*






*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌដូនពេញ*

សង្កាត់ ឆ្នាំ២០២២ នាពេលខាងមុខ ព្រមទាំងបន្តទប់ស្កាត់រាល់បញ្ហាអសកម្មទាំងឡាយណា ដែលកើតមានឡើងនៅក្នុងមូលដ្ឋាន ដើម្បីចូលរួមការពារផលប្រយោជន៍ និងសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** បានបញ្ជាក់ថា អាស្រ័យដោយប្រទេសជាតិយើងមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការប្រកបដោយប្រសិទ្ធភាព ធ្វើឱ្យប្រទេសយើងអាចឆ្លងផុតប្រកបដោយសុវត្ថិភាពនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានផ្តាំផ្ញើ និងក្រើនរម្លឹកដល់អាជ្ញាធរខណ្ឌទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងថ្មីប្រភេទអូមីក្រុងជូនដល់ប្រជាពលរដ្ឋ ហើយក៏កុំទាន់ធ្វេសប្រហែសឱ្យសោះចំពោះជំងឺនេះ “យើងអាចភ្លេចជំងឺកូវីដ-១៩ តែជំងឺនេះមិនដែលភ្លេចយើងទេ” ដូច្នេះត្រូវប្រកាន់ខ្ជាប់វិធានការ ៣កុំ និង៣ការពារ៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)





*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ជាអធិបតីភាពក្នុងពិធីសំណេះសំណាលនៅខណ្ឌបឹងកេងកង*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃសុក្រ ទី៤ ខែមីនា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គទាំងទ្វេ ស្តេចយាងទៅពិនិត្យព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។



❈នាល្ងាចថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពអគ្គមហាឧបាសក **លឹម ឈុន** ឪពុកបង្កើតឧកញ៉ា **អ៊ឹង ប៊ុនហ៊ាង** ដែលបានទទួលមរណភាព កាលពីវេលាទៀបភ្លឺ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ក្នុងជន្មាយុ៩៧ឆ្នាំ ដោយជរាពាធ។



❈នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ទាំង៧ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំង៥ ក្នុងខណ្ឌចំការមន នៅសាលប្រជុំសាលាខណ្ឌចំការមន រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំង១២ ក្នុងខណ្ឌដង្កោ នៅសាលប្រជុំសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំង៧ ក្នុងខណ្ឌមានជ័យ នៅសាលប្រជុំសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ៕



# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលក្រុមប្រឹក្សាឃុំ ក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលអាជ្ញាធរស្រុកជើងព្រៃ*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាស្រុក ឃុំ មកពីស្រុកជើងព្រៃ ស្រុកបាធាយ និងស្រុកព្រៃឈរ ខេត្តកំពង់ចាមចំនួន២៦១នាក់ និងសមាជិក សមាជិកាក្រុមប្រឹក្សាស្រុក ឃុំ មកពីស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ និងស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំចំនួន២៨៥នាក់ កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។

ពិធីសំណេះសំណាលនេះ រៀបចំឡើង ដើម្បីក្តាប់នូវស្ថានការណ៍ជាក់ស្តែង ពិនិត្យតាមដានយន្តការនៃការអនុវត្តកម្មវិធីនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ព្រមទាំងការត្រៀមខ្លួន ដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

ក្នុងឱកាសជួបសំណេះសំណាលដោយឡែក នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំ បានធ្វើសេចក្តីរាយការណ៍ជូនក្រុមសមាជិកព្រឹទ្ធសភាជ្រាប អំពីវិធានការ នៃការអនុវត្តគោលនយោបាល ភូមិ ឃុំមានសុវត្ថិភាព ការពង្រឹងសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការចូលរួមដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការ។

ក្នុងពិធីសំណេះសំណាលនោះ ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធទាំងពីរខេត្ត ដែលបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងបានគ្រប់គ្រងដោះស្រាយរាល់បញ្ហាទុក្ខកង្វល់ និងសំណូមពរនានារបស់បងប្អូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងល្អ។ ឯកឧត្តមប្រធានបានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអាជ្ញាធរស្រុកជើងព្រៃ*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលអាជ្ញាធរស្រុកត្បូងឃ្មុំ*

ប្រសើរ និងមានទំនុកចិត្ត មានភាពជឿជាក់ពីសំណាក់បងប្អូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចមូលដ្ឋាន ដែលខ្លួនគ្រប់គ្រង ព្រមទាំងជំរុញ និងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ។

ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានលើកទឹកចិត្តដល់ក្រុមប្រឹក្សា អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ជាមួយនឹងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង ហើយបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ សម្រាប់ចូលរួមបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ នាពេលខាងមុខ។ ជាមួយគ្នានោះ ឯកឧត្តមក៏បានក្រើនរំលឹកដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ សូមចូលរួមផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ជាពិសេសមេរោគបំប្លែងថ្មីប្រភេទអូមីក្រុង និងជំរុញបងប្អូនប្រជាពលរដ្ឋណា ដែលមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សូមទៅទទួលការចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា ព្រមទាំងបន្តធ្វើការផ្សព្វផ្សាយអប់រំ និងណែនាំ បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យប្រកាន់ខ្ជាប់នូវវិធានការ៣កុំ ៣ការពារ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការកាត់ផ្តាច់ឱ្យអស់នូវការឆ្លងជំងឺនេះចូលក្នុងសហគមន៍៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលនៅស្រុកត្បូងឃ្មុំ*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរស្រុកត្បូងឃ្មុំ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលក្រុមប្រឹក្សាឃុំ ក្នុងស្រុកមេមត់ ស្រុកពញាក្រែក និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលអាជ្ញាធរស្រុកមេមត់*

កាលពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញជួបសំណេះ-សំណាលជាមួយអាជ្ញាធរស្រុក ប្រធានក្រុមប្រឹក្សាក្រុងស្រុក និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ នៅស្រុកមេមត់ចំនួន១០៣នាក់ ស្រុកពញាក្រែកចំនួន៧៨នាក់ និងស្រុកតំបែរចំនួន៥៤នាក់ នៅខេត្តត្បូងឃ្មុំ ដើម្បីក្តាប់នូវស្ថាន-ការណ៍ជាក់ស្តែងប្រមូលព័ត៌មានលើការងារអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ចំពោះគោលនយោបាយ ភូមិឃុំមានសុវត្ថិភាពទាំង៧ចំណុច ព្រមទាំងការត្រៀមខ្លួនដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ នាពេលខាងមុខ។

ក្នុងឱកាសសំណេះសំណាលដាច់ដោយឡែកនៅស្រុកនីមួយៗ អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំ បានធ្វើសេចក្តីរាយការណ៍ជូនក្រុមសមាជិកព្រឹទ្ធសភាជ្រាប អំពីវិធានការនៃការអនុវត្តគោលនយោបាល ភូមិ ឃុំមានសុវត្ថិភាព ការពង្រឹងសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការចូលរួមដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការ បញ្ហាប្រឈម និងសំណូមពរនានារបស់អាជ្ញាធរមូលដ្ឋាន។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធដែលបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងបានដោះស្រាយរាល់បញ្ហាទុក្ខកង្វល់ និងសំណូម-ពរនានារបស់បងប្អូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងល្អ។ ឯកឧត្តមបានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ និងមានទំនុកចិត្ត មានភាពជឿជាក់ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ព្រមទាំងជំរុញ និងអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ។

ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានលើកទឹកចិត្តដល់ក្រុម-ប្រឹក្សា អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ជាមួយនឹងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង ហើយបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលអាជ្ញាធរស្រុកពញាក្រែក*

ត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ សម្រាប់ទៅចូលរួមបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ នាពេលខាងមុខ។ ជាមួយគ្នានោះ ឯកឧត្តមសូមឱ្យអាជ្ញាធរមានសមត្ថកិច្ច សមាជិកក្រុមប្រឹក្សាឃុំទាំងអស់ត្រូវបន្តពង្រឹងការអនុត្តគោលនយោយបាយភូមិ ឃុំមានសុវត្ថិភាពឱ្យបានខ្លាំងក្លា និងល្អប្រសើរថែមទៀត ជាពិសេសយកចិត្តទុកដាក់ក្នុងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅតាមឃុំរបស់ខ្លួនឱ្យបានម៉ត់ចត់ និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនោះដែរសូមក្រុមប្រឹក្សាឃុំទាំងអស់ត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ខាង-មុខ។

ឯកឧត្តមបានក្រើនរំលឹកដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ក្រុមប្រឹក្សាឃុំទាំងអស់ ត្រូវផ្សព្វផ្សាយ និងជំរុញដល់ប្រជាពលរដ្ឋទាំងអស់ត្រូវចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣កុំ ៣ការពារ និងជំរុញបងប្អូនប្រជាពលរដ្ឋណា ដែលមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សូមទៅទទួលការចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអាជ្ញាធរស្រុកតំបែរ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលអាជ្ញាធរឃុំ ក្នុងស្រុកស្វាយលើ និងស្រុកសូទ្រនិគម ខេត្តសៀមរាប



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដឹកនាំដោយឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលអាជ្ញាធរស្រុក ក្រុម-ប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងប្រធានភូមិ ក្នុងស្រុកស្វាយលើ និងស្រុកសូទ្រនិគម ខេត្តសៀមរាប សរុបចំនួន២៩៣នាក់ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌-មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត បញ្ហាកង្វល់ បញ្ហាប្រឈម តម្រូវការ និងសំណូមពរជុំវិញការផ្ដល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការធ្វើអត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិ-អភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។

បន្ទាប់ពីលោកអភិបាលស្រុកស្វាយលើ និងស្រុកសូទ្រ-និគម ធ្វើសេចក្ដីរាយការណ៍រួចមក ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងប្រធានភូមិ បន្តអនុវត្តតួនាទីរបស់ខ្លួននៅក្នុងមូល-ដ្ឋានដោយផ្ដោតលើការផ្ដល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ និងការអនុវត្តគោល-នយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បញ្ហាប្រឈមតម្រូវការ សំណូមពររបស់ប្រជាពលរដ្ឋ ការចាក់វ៉ាក់សាំង



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអាជ្ញាធរឃុំ ក្នុងស្រុកស្វាយលើ ខេត្តសៀមរាប*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលអាជ្ញាធរឃុំ ក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប*

កូវីដ-១៩ ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងរងគ្រោះដោយសារជំងឺកូវីដ-១៩ បញ្ហាប្រឈមពាក់ព័ន្ធលើដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងបទល្មើសនានា។

ឯកឧត្តម **ម៉ុល លីម** បានបញ្ជាក់ថា ចំពោះបញ្ហា និងសំណូមពរដែលបានលើកឡើងក្នុងឱកាសនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងយកទៅជម្រាបជូនអាជ្ញាធរស្រុក និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ដើម្បីរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា។ បើសិនជាស្រុក និងមន្ទីរពាក់ព័ន្ធមិនអាចដោះស្រាយបាន ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងពាំនាំយកបញ្ហាប្រឈម និងសំណូមពទាំងអស់មកជូនអាជ្ញាធរខេត្ត ដើម្បីធ្វើការដោះស្រាយបន្ត។

ឯកឧត្តម **ម៉ុល លីម** បានថ្លែងនូវការកោតសរសើរចំពោះអាជ្ញាធរស្រុកទាំងពីរ ទាក់ទងនឹងភូមិឃុំមានសុវត្ថិភាព គឺពុំមានគ្រឿងញៀន ពុំមានអំពើហិង្សាក្នុងគ្រួសារ និងគ្រោះថ្នាក់ចរាចរណ៍។

ឯកឧត្តមបានផ្ដាំផ្ញើដល់អាជ្ញាធរទាំងអស់ ត្រូវថែទាំសុខភាពផ្ទាល់ខ្លួន ក្រុមគ្រួសារ និងសហគមន៍ ជាពិសេសត្រូវអនុវត្តវិធានការ ៣កុំ ៣ការពារ ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ និងអញ្ជើញទៅចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នា៕

(អត្ថបទ និងរូបភាព៖ គីម សិទ្ធី)



*ឯកឧត្តម ម៉ុល លីម មានមតិសំណេះសំណាល*



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអាជ្ញាធរឃុំ ក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តកំពត និងខេត្តកែប




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលអាជ្ញាធរខេត្តកំពត*

កាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដឹកនាំដោយឯកឧត្តម **ខៀវ មុត** ប្រធានក្រុម បានអញ្ជើញចុះជួបសំណេះ-សំណាលជាមួយនឹងថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ មកពីក្រុងបូកគោ ស្រុកទឹកឈូ ស្រុកឈូក និងស្រុកជុំគិរី ខេត្តកំពត សរុប៣៦៨នាក់ និងថ្នាក់ដឹកនាំខេត្ត ក្រុង សមាជិក សមាជិកាក្រុម-ប្រឹក្សាឃុំ សង្កាត់ ស្រុក មកពីស្រុកដំណាក់ចង្អើរ ស្រុកកំពង់-ត្រាច ស្រុកដងទង់ ស្រុកអង្គរជ័យ និងស្រុកបន្ទាយមាស ខេត្តកែបសរុប៨៧នាក់ នៅខេត្តកំពត និងខេត្តកែប។

ពិធីសំណេះសំណាលនេះ រៀបចំឡើងដើម្បីឈ្វេងយល់ ប្រមូលព័ត៌មានពីការអនុវត្តការងាររបស់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ការគាំទ្រ ការអភិវឌ្ឍនានារបស់ឃុំ សង្កាត់ ស្តាប់រាល់បញ្ហាប្រឈម និងសំណូមពរនានាជុំវិញការអនុវត្តតួនាទី ភារកិច្ចរបស់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ការប្រមូលផ្តុំកម្លាំងត្រៀមសម្រាប់ធ្វើសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

ក្នុងឱកាសសំណេះសំណាលដាច់ដោយឡែកពីគ្នា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានស្តាប់សេចក្តីរាយការណ៍របស់ថ្នាក់ដឹកនាំខេត្ត មន្ទីរពាក់ព័ន្ធជុំវិញខេត្ត អំពីវិធានការ នៃការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ការពង្រឹងសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ បានចូលរួមដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលា-ការ ការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ព្រមទាំងការងារសុខុមាលភាព ការអនុវត្តវិធានការប្រយុទ្ធ និងទប់-ស្កាត់ជំងឺកូវីដ-១៩ផងដែរ។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ឯកឧត្តម **ខៀវ មុត** ប្រធានក្រុម បានពាំនាំនូវការសួរសុខ-ទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំ និងប្រជា-ពលរដ្ឋរស់នៅក្នុងខេត្តកំពត និងខេត្តកែប។ ឯកឧត្តម **ខៀវ មុត** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក សមាជិកសមាជិកាក្រុម-ប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរពាក់ព័ន្ធខេត្តទាំងពីរ ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនបានយ៉ាងសកម្ម ធ្វើឱ្យខេត្តទាំងពីរមានការប្រែមុខ ប្រែមាត់ថ្មី ព្រមទាំងតាមមូលដ្ឋានក៏មានការអភិវឌ្ឍ និងការរីកចម្រើន។ ជាមួយគ្នានេះ ខេត្តបានចូលរួមដោះស្រាយនូវរាល់បញ្ហាទុក្ខកង្វល់ និងសំណូមពរនានារបស់បងប្អូនប្រជាពលរដ្ឋ ដែលបានជួបការលំបាកក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយគ្រប់-គ្រងបានយ៉ាងល្អ។

ឯកឧត្តមបានបញ្ជាក់ថា ឆ្នាំ២០២២នេះ ក៏ជាឆ្នាំ នៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ហេតុដូចនេះ សូមសមាជិក សមាជិកាក្រុម-ប្រឹក្សាសង្កាត់ទាំងអស់ត្រូវតែក្តាប់ឱ្យជាប់រាល់ផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោត ដែលថ្នាក់លើបានណែនាំ និងតាមដានអនុវត្តឱ្យបានល្អ តាមប្រតិទិននៃការបោះឆ្នោតរបស់ គ.ជ.ប។ ចំពោះរាល់បញ្ហាប្រឈម ការលំបាកខ្វះខាតដែលមូលដ្ឋានបានជួបប្រទះ ត្រូវរួសរាន់ដោះស្រាយឱ្យបានឆាប់រហ័ស និងមានតម្លាភាព ហើយបញ្ហាណាដែលហួសពីសមត្ថកិច្ចរបស់ខ្លួនដោះស្រាយ សូមសុំយោបល់ពីថ្នាក់ដឹកនាំ ដើម្បីស្វែងរកយន្តការ នៃការដោះ-




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលអាជ្ញាធរខេត្តកែប*

ស្រាយបន្ត។

ឯកឧត្តម **ខៀវ មុត** បានធ្វើការផ្ដាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការផ្ដល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ និងមានទំនុកចិត្ត មានភាពជឿជាក់ពីសំណាក់បងប្អូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនត្រូវគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល ព្រមទាំងជំរុញ និងអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការរក្សាសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋក្នុងខេត្តរបស់ខ្លួន។

ឯកឧត្តម **ខៀវ មុត** បានក្រើនរំលឹកដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ សូមចូលរួមណែនាំ និងផ្សព្វផ្សាយបន្តនូវវិធានការការពារ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រភេទបំប្លែងថ្មី អូមីក្រុង និងឱ្យប្រញាប់ប្រញាល់ទៅទទួលការចាក់វ៉ាក់សាំងដូសជំរុញលើកទី៣ ឬលើកទី៤ ព្រមទាំងនាំកូនចៅរបស់ខ្លួនទៅចាក់វ៉ាក់សាំងឱ្យបានគ្រប់ៗគ្នា និងត្រូវរៀនរស់ជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ជាពិសេសអនុវត្តវិធានការ ៣ការពារ ៣ កុំ ឱ្យបានម៉ត់ចត់តាមការណែនាំរបស់ក្រសួងសុខាភិបាល។

ក្រៅពីចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរទាំងពីរខេត្ត ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកទេយ្យទាន ប្រគេនដល់វត្តសុវណ្ណសាគរ វត្តសុវណ្ណមិគ្គា ហៅវត្តស្រះចាស់ ក្នុងខេត្តកំពត និងវត្តគគីជុំភ្នំខ្វារ វត្តឧទុម្ពរកំពង់ត្រាច និងវត្តភ្នំត្រែល ក្នុងខេត្តកែប ព្រមទាំងបានប្រគេនក្នុងមួយវត្តៗរួមមាន៖ អង្ករ៥០គីឡូក្រាម មី១កេស ត្រីខកំប៉ុង១យួរ ទឹកផ្លែឈើ១កេស ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ ទឹកបរិសុទ្ធ១កេស បច្ច័យមួយចំនួន និងចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន៥០គ្រួសារ នៅខេត្តទាំងពីរ ដោយក្នុងមួយគ្រួសារៗ ទទួលបាន៖ មី១កេស ត្រីខកំប៉ុង១យួរ ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ ក្រមា១ និងថវិកាមួយចំនួន។

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទ៥ សំណេះសំណាលអាជ្ញាធរឃុំ ស្រុកអង្គរជ័យ និងស្រុកបន្ទាយមាស*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាល ក្រុមប្រឹក្សាឃុំ ក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលអាជ្ញាធរស្រុកកោះញែក*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញចុះពិនិត្យស្ថានការណ៍ជាក់ស្តែង នៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ បញ្ហាប្រឈម និងសំណូមពរនានារបស់អាជ្ញាធរមូលដ្ឋាន ដែលបាននឹងកំពុងជួបប្រទះក្នុងការអនុវត្តការងារកន្លងទៅ ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ការប្រកបរបរអាជីវកម្មរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ផែនការសកម្មភាពរបស់ឃុំ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការទប់ស្កាត់ជំងឺកូវីដ-១៩ នៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។

ការចុះពិនិត្យស្ថានការណ៍ជាក់ស្តែងនោះ បានប្រព្រឹត្តទៅក្នុងឱកាសដែលក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ទាំង៦ឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលសរុបចំនួន៤២នាក់ នៅសាលប្រជុំសាលាស្រុកកោះញែក ខេត្តមណ្ឌលគិរី នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២។

នៅក្នុងឱកាសនោះ លោកអភិបាលស្រុកកោះញែក និងលោកមេឃុំទាំង៦ ក្នុងស្រុកកោះញែក បានឡើងធ្វើសេចក្តីរាយការណ៍ជូនអង្គពិធីអំពី វឌ្ឍនភាពរបស់ស្រុក និងការយកចិត្តទុកដាក់ក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរមួយចំនួនដែលនៅសេសសល់។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ឯកឧត្តម **យ៉ង់ សែម** បានថ្លែងនូវការកោតសរសើរចំពោះអាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ ដែលបានខិតខំ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ថតរូបអនុស្សាវរីយ៍ជាមួយនឹងអាជ្ញាធរស្រុកកោះញែក*

បំពេញតួនាទី ភារកិច្ចរបស់ខ្លួនបម្រើប្រជាពលរដ្ឋ និងអភិវឌ្ឍន៍មូលដ្ឋាន។ ឯកឧត្តមបានជំរុញឱ្យអាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ត្រូវខិតខំរួមសហការគ្នាជំរុញដោះស្រាយនូវបញ្ហាប្រឈម សំណូមពរនានាដែលនៅសេសសល់ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ហើយបញ្ហាណាដែលហួសពីដែនសមត្ថកិច្ចនោះ សូមលើកស្នើតាមឋានានុក្រមទៅសមត្ថកិច្ចស្រុក ក្រុង ខេត្ត ដើម្បីជួយរកដំណោះស្រាយ។

ឯកឧត្តម **យ៉ង់ សែម** បានបញ្ជាក់ថា អាជ្ញាធរនៅថ្នាក់ក្រោមជាតិទាំងអស់ ជាអ្នកបម្រើជួរមុខនៅក្នុងមូលដ្ឋាន ត្រូវខិតខំបង្កើនសមត្ថភាព ត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ ស្អាតស្អំ គោរពច្បាប់ មិនរើសអើង ខិតខំរិះរកការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ដើម្បីធ្វើយ៉ាងណាឱ្យទទួលបានការគោរពស្រឡាញ់ និងជំនឿទុកចិត្តពីប្រជាពលរដ្ឋ។ ក្រៅពីនេះ ត្រូវជួយចូលរួមបំផុសចលនាដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឱ្យចូលរួមការពារទប់ស្កាត់ និងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងថែរក្សាឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឯកសារអត្រានុកូលដ្ឋាន និងឯកសារសម្គាល់អត្តសញ្ញាណកម្មសម្រាប់បម្រើឱ្យការបោះឆ្នោត ព្រមទាំងអប់រំកូនចៅឱ្យខិតខំរៀនសូត្ររស់នៅឱ្យឆ្ងាយពីគ្រឿងញៀន។

ក្នុងដំណើរបេសកកម្មនៅទឹកដីខេត្តមណ្ឌលគិរី ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បាននាំទេយ្យទានគ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួន ប្រគេនព្រះសង្ឃគង់ក្នុងវត្តទីប្រាំបួន ព្រមទាំងនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចែកជូនដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន៦គ្រួសារ ស្ថិតក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី ដោយក្នុងមួយគ្រួសារៗទទួលបានចំនួន១ឃីត និងថវិកាមួយចំនួន៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ នាំយកទេយ្យទានប្រគេនព្រះសង្ឃ និងចែកអំណោយជូនប្រជាពលរដ្ឋ ក្នុងស្រុកកោះញែក*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❋ឯកឧត្តម **យង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យពិភាក្សាលើបញ្ហាផ្សេងៗ ព្រមទាំងស្ដាប់ការចូលរួមជាមតិយោបល់ពីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីត្រៀមជួបសំណេះ-សំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំទាំង៦ ក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។



-ប្រជុំជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមក្រុមភូមិភាគទី៨ ដើម្បីពិនិត្យលើរបាយការណ៍ស្ដីពី ការសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ និងស្រុកកោះញែក ខេត្តមណ្ឌលគិរី នាថ្ងៃទី២៤ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

-ប្រជុំជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមក្រុមភូមិភាគទី៨ នៅសាលគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីពិនិត្យ និងពិភាក្សាត្រៀមចុះបេសកកម្មទៅតាមស្រុកនីមួយៗ និងការងារផ្សេងៗ នៅសាលប្រជុំគណៈ-



កម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។



-ប្រជុំជាមួយនឹងក្រុមមន្ត្រីពាក់ព័ន្ធ ដើម្បីត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤ (IPU-144) នៅសាលប្រជុំគណៈកម្មការទី១ ព្រឹទ្ធសភា នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។



❋នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជា ខេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិនិត្យ ពិភាក្សាលើការងារចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❋លោកជំទាវ **ឌី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាថ្ងៃទី២៣ ខែកុម្ភៈ

ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលនៃកិច្ចប្រជុំជាមួយនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២។

២-របាយការណ៍អំពីគម្រោងចុះបំពេញបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

៣-ការបិទបញ្ជីចំណូល-ចំណាយថវិការបស់គណៈកម្មការប្រចាំខែកុម្ភៈ ឆ្នាំ២០២២។

៤-បញ្ហាផ្សេងៗ។



-ការដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលសកម្មភាពការងាររបស់គណៈកម្មការទី៥ ប្រចាំខែមីនា ឆ្នាំ២០២២។

២-ការបូកសរុបលទ្ធផលការងារព័ត៌មានអន្តរជាតិ និងដំណើរបំពេញទស្សនកិច្ចរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទ្វីបអឺរ៉ុប និងមជ្ឈិមបូព៌ា (តួកគី)។

៣-របាយការណ៍អំពីព្រឹត្តិការណ៍អន្តរជាតិការធ្វើសង្គ្រាមរវាងប្រទេសរុស្ស៊ីជាមួយនឹងប្រទេសអ៊ុយក្រែន។

៤-របាយការណ៍អំពីបេសកកម្មនៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២ និងបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

៥-បញ្ហាផ្សេងៗ។



❋នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីស្ដាប់របាយការណ៍លទ្ធផលចុះសំណេះសំណាលនៅស្រុកបាធាយ ស្រុកជើងព្រៃ ស្រុកព្រៃឈរ ខេត្តកំពង់ចាម និងនៅស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងពិនិត្យកម្មវិធីគម្រោងចុះសំណេះសំណាលនៅក្រុងកំពង់ចាម ស្រុកកំពង់សៀម ស្រុកកងមាស ស្រុកកោះសូទិន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងនៅស្រុកមេមត់ ស្រុកពញាក្រែក ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ស្ថិតនៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-ការពិភាក្សាអំពីកម្មវិធីចុះបេសកកម្មក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង។

២-ការទូទាត់ចំណូល-ចំណាយថវិការបស់ក្រុម ប្រចាំត្រីមាសទី១ ឆ្នាំ២០២២។

៣-បញ្ហាផ្សេងៗ។



-ការដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា តាមប្រព័ន្ធវីដេអូ (Zoom) នារសៀលថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-គម្រោងចុះបេសកកម្មរបស់គណៈកម្មការទី៨ព្រឹទ្ធសភា នៅក្នុងរយៈពេលចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ នាពេលខាងមុខ។

២-ការទូទាត់ចំណូល-ចំណាយថវិការបស់គណៈកម្មការទី៨ព្រឹទ្ធសភា ប្រចាំត្រីមាសទី១ ឆ្នាំ២០២២។

៣-បញ្ហាផ្សេងៗ។



❈នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារ របាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែមីនា ឆ្នាំ២០២២ និងគម្រោងចុះបំពេញបេសកកម្មនៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយនឹងមជ្ឈមណ្ឌលសភាអាស៊ី (PC Asia) ស្តីពីការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី “សិទ្ធិកាន់កាប់ដីធ្លី ការអនុវត្តច្បាប់ដីធ្លី និងកាលានុវត្តភាព នៃការអនុវត្តគោលនយោបាយសាធារណៈផ្នែកដីធ្លី ដើម្បីជាកត្តារួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផលប្រយោជន៍របស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា” តាមប្រព័ន្ធនិម្មិត (Zoom) នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ៖

-ឆ្លងរបាយការណ៍លទ្ធផលវគ្គបំប៉នពង្រឹងសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំមន្ទីរ ខណ្ឌ សង្កាត់ នៃរាជធានីភ្នំពេញ តាមប្រព័ន្ធវីដេអូ (Zoom) នារសៀលថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។

-សមាគមនារីរាជធានីភ្នំពេញ តាមប្រព័ន្ធវីដេអូ (Zoom) នារសៀលថ្ងៃទី១ ខែមីនា ឆ្នាំ២០២២៕

## ការទទួលពាក្យបណ្តឹង

❈នៅក្នុងខែមីនា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៣ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៦ករណី កំពុងពិនិត្យសិក្សាចំនួន៦ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៣ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨



❋នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ខាវ ខេង** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលស្ដីពី ច្បាប់ បទបញ្ញា និងនីតិវិធីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងទទួលអំណោយសត្វក្ងោកញីចំនួន១ក្បាល ពីលោក **ស៊ិន ចំរើន** សម្រាប់រក្សាទុកក្នុងតំបន់រមណីយដ្ឋានកសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលការរៀបចំទីតាំងដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបចំណេះសំណាល និងសួរសុខទុក្ខក្រុមការងារគ្រឿងចក្រជួសជុលផ្លូវធ្វើដំណើរពីខាងមុខព្រះវិហារវត្តដំណាក់សម្ដេចឪ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារកសិកម្ម រួមជាមួយវិស្វករសំណង់ ចុះពិនិត្យ និងដាក់ផែនការការងារអភិវឌ្ឍន៍បន្តទៀត នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធ សំណង់ទំនប់ទឹក ផ្លូវនានា ព្រមទាំងណែនាំកម្មករអំពីរបៀបថែទាំផ្លែស្វាយ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាសួនសត្វនៅតំបន់អភិវឌ្ឍន៍ម៉ុង ឫទ្ធីសែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។

-ចុះជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ និងកុមារាកុមារី នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នៅភូមិស្វាយ នាព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ទទួលអំណោយកំព្យូទ័រចំនួន២០គ្រឿង និងប្រដាប់វិនិច្ឆ័យរកមេរោគសត្វ ពី Mr Boonsarng Prasitphol សម្រាប់យកមកបង្រៀននិស្សិតបំពេញចំណេះវិជ្ជាលើវិស័យកសិកម្ម និងឧស្សាហកម្ម នៅវិទ្យាស្ថានកសិកម្ម ឧកញ៉ា ម៉ុង ឫទ្ធី កែវផុស នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យ និងជំរុញការងារស្ថាបនាផ្លូវ និងការងារសាងសង់ប្រាសាទព្រះវិហារនិមិត្តរូប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។

-ចុះជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យ និងជំរុញការងារស្ថាបនាផ្លូវ និងសំណង់នានា នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។




❋លោកជំទាវ **ទី ឫទ្ធីស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខលោកស្រី នាងកញ្ញា មន្ត្រីឃុំទទួលបន្ទុកកិច្ចការនារី និងលោកគ្រូ អ្នកគ្រូ កុមារា កុមារី សិស្សក្រីក្ររៀនពូកែ ដើម្បីអបអរសាទរទិវា

នារីអន្តរជាតិ៨មីនាលើកទី១១១ ព្រមទាំងនាំយកថវិកាមួយចំនួន និងសម្ភារមួយចំនួន រួមមាន៖ ទោចក្រយានចំនួន១០ ម៉ាស់ចំនួន៦០០ សារុងចំនួន១១ សៀវភៅចំនួន៨០ក្បាល ប៊ិចចំនួន៨០ដើម ខ្មៅដៃ១០ដើម នៅឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង១១ ចំនួន ២០២នាក់ ព្រមទាំងជួបសំណេះសំណាលគណៈអ៊ីម៉ាំ ស្រុកហាគីមទូនវិហារឥស្លាមទាំង៥ ក្នុងស្រុក និងបងប្អូនសាសនិកឥស្លាមដែលមានជីវភាពមិនសូវធូរធារចំនួន៦២នាក់ ព្រមទាំងបាននាំយកនូវថវិកាមួយចំនួន និងសម្ភារមួយចំនួនរួមមាន៖ សារុងចំនួន៣០០ ក្រមាចំនួន១៥ ម៉ាស់ចំនួន១៦.៥០០ ថ្នាំពេទ្យ២៥០ប្រអប់ អង្ករ៥០០គីឡូក្រាម និងត្រីខចំនួន៦០០កំប៉ុង នៅសាលាស្រុកពញាឮ ខេត្តកណ្តាល នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ ប្រធានភូមិ ព្រមទាំងប្រជាពលរដ្ឋ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅក្នុងភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។



❋ឯកឧត្តម **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ និងប្រធានភូមិ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ការងារផ្តល់សេវាសាធារណៈ និងការត្រៀមលក្ខណៈរបស់ក្រុមប្រឹក្សាសង្កាត់ក្នុងការចូលរួមបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅសាលាសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។



❋នារសៀលថ្ងៃទី២៤ និងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធាន និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពថ្នាក់ដឹកនាំស្ត្រី ក្រុង ស្រុក ឃុំ សង្កាត់ នៅសាលប្រជុំសាលាខេត្តកណ្តាល។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីប្រកាសកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តពោធិ៍សាត់ នៅទីរួមខេត្តពោធិ៍សាត់ នារសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខ និងនាំយកអំណោយ ជូនដល់លោកតា លោកយាយចាស់ជរា និងប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន៣៥គ្រួសារ រស់នៅក្នុងភូមិទួលជ្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នារសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជាកិត្តិយសក្នុង៖




-ពិធីអបអរសាទរខួបអនុស្សាវរីយលើកទី១១១ នៃទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ក្រោមប្រធានបទ៖ "សមភាពយេនឌ័រ ថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត" នៅឃុំដើមឫស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។



-កិច្ចប្រជុំជាមួយនឹងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកកណ្ដាលស្ទឹង ក្រោមអធិបតីភាពឯកឧត្តមកិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** ប្រធានក្រុមការងាររាជរដ្ឋាភិបាល ដើម្បីពិនិត្យវាយតម្លៃអំពីសកម្មភាពរបស់ក្រុម ការងារចុះជួយដល់អាជ្ញាធរស្រុក ឃុំ ភូមិ និងប្រជាពលរដ្ឋ ស្ថិតនៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីរៀបចំកិច្ចការសំខាន់ៗឆ្ពោះទៅកាន់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ នៅឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលរវាងក្រុមតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែងជាមួយនឹងក្រុមការងារឃុំទូទាំងស្រុកពាមរក៍ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា នៅភូមិព្រែកខ្សាយ ឃុំព្រែកខ្សាយ ស្រុកពាមរក៍ ខេត្តព្រៃវែង នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ របស់រដ្ឋបាលខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាខេត្តបាត់ដំបង នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។

❋នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារនៅថ្នាក់ខេត្ត ក្រុងខេមរភូមិន្ទ និងសង្កាត់ទាំងបី គឺ៖សង្កាត់ស្មាច់មានជ័យ សង្កាត់ដងទង់ និងសង្កាត់ស្ទឹងវែង ព្រមទាំងបានផ្ដល់ជូនថវិកាមួយចំនួនដល់សង្កាត់ទាំងបីផងដែរ នៅក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទាំង១០ ក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីពិនិត្យលទ្ធផល



ការងារខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ២០២២ ដោយត្រួតពិនិត្យលើផ្នែកសន្តិសុខសណ្តាប់ អនាម័យសាធារណៈ ការផ្សព្វផ្សាយវិធានការ និងការត្រៀមលក្ខណៈចាត់ចែងការងារឱ្យបានទាន់ពេល ស្របតាមប្រតិទិនការងាររបស់ គ.ជ.ប នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខភរិយា លោក **សេខ សាវ៉ាន់** ប្រធានក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត នាព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំជាមួយនឹងប្រធានសមាគមមនុស្សចាស់ និងគណៈកម្មការកិច្ចការស្ត្រី និងកុមារ ដើម្បីស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារក្នុងខែកុម្ភៈ និងទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២២ នាព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ សរុបចំនួន៥០នាក់ ដើម្បីប្រារព្ធខួបទី១១១ នៃទិវាអន្តរជាតិនារី ស្ថិតនៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។





-ចូលរួមកិច្ចប្រជុំ ដើម្បីស្តាប់របាយការណ៍ស្តីពី វឌ្ឍនភាពការងារសុខដុមនីយកម្មសាសនារាជធានីភ្នំពេញ ប្រចាំខែមីនា និងទិសដៅជាអាទិភាពខែមេសា ឆ្នាំ២០២២ តាមប្រព័ន្ធ (Zoom) នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។



-ជួបសំណេះសំណាលលើកទឹកចិត្តក្មួយៗ និងចៅៗ ជាមន្ត្រី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយក្តីស្រឡាញ់ពេញចិត្ត និងសូមកោតសរសើរ ដែលបានទៅចាក់វ៉ាក់សាំងតាមគោលការណ៍ស្ម័គ្រចិត្តរបស់រាជរដ្ឋាភិបាល នូវដូសមូលដ្ឋាន និងដូសជំរុញ (ដូសទី៤) បានរួចរាល់គ្រប់ៗគ្នា នៅវិមានព្រឹទ្ធសភា នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២។

❋នាព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញនាំយកទេយ្យទានជាគ្រឿងឧបភោគ បរិភោគ សម្ភារ និងបច្ច័យទៅប្រគេនព្រះសង្ឃគង់នៅវត្តព្រៃពួច ស្ថិតក្នុងឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខគ្រួសារ នៃសព ចំនួនពីរគ្រួសារ នៅភូមិត្រពាំងរុន និងភូមិព្រីងជ្រំ ដែលក្នុងមួយគ្រួសារ នៃសព

ទទួលបាន៖ អង្ករ មី ត្រីខកំប៉ុង និងថវិកាមួយចំនួន ព្រមទាំងជូនចាស់ៗ លោកប្រធានភូមិទាំងពីរ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ដែលបម្រើឱ្យការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ព្រមទាំងចូលរួមរំលែកទុក្ខគ្រួសារនៃសពមួយគ្រួសារ ព្រមទាំងបានចុះជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះចំនួន៦ភូមិ និងបានចែកជូនសម្ភារមួយចំនួនរួមមាន៖ សារុង ក្រមា នាឡិកា នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួន ឧបត្ថម្ភជូនដល់ក្រុមការងារចុះជួយខេត្តកំពង់ស្ពឺ សម្រាប់បម្រើយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលខាងមុខ នាព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោក **អ៊ូ យ៉ុខ** សមាជិកក្រុមប្រឹក្សាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងលោកជំទាវ **កែវ សុខុម** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ និងក្រុមគ្រួសារ ម្ដាយបង្កើតរបស់លោកជំទាវ ដែលបានទទួលមរណភាព នៅភូមិត្រស់សាលាសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោក **ពៅ នូ** សមាជិកក្រុមប្រឹក្សាស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិភារី ឃុំរលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារ ឯកឧត្តម **អ៊ុក គោសា** ដែលកូនប្រុសទើបទទួលមរណភាព និងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិរលាំងសង្កែ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យបញ្ចុះសីមា និងសម្ពោធសមិទ្ធផលនានាក្នុងវត្តក្រាំងតាវ័ន្ត នៅឃុំញ្ញាយ ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

❈នាថ្ងៃទី១១ និងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

❈នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះខណ្ឌសីមា និងឆ្លងសមិទ្ធផលនានា នៅវត្តសំរោងវ័ន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ីង ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ស្ថិតក្នុងឃុំពេជសារ ស្រុកកោះអណ្ដែត ខេត្តតាកែវ ។




❈នាថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញចូលរួមក្នុងពិធីសន្និបាតសមាគមមូល-និធិមនុស្សចាស់ ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

❈នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យប្រជាជន នៅភូមិចក សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

❈នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាគណៈអធិបតីភាពក្នុងពិធី



សម្ពោធឆ្លងមហាកុដិ និងសមិទ្ធផលនានាក្នុងវត្តឧឪទុម្ពរ (ហៅវត្តល្វា) ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក ស្ថិតនៅភូមិស្វាធំ ឃុំល្មៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។



❋នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីសម្ពោធ និងប្រគល់ស្នែនបាសាំងទឹកចំនួន៧ ជូនអាជ្ញាធរមូលដ្ឋាន នៅក្នុងឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះពិនិត្យការដ្ឋានសាងសង់អគារសាលាបឋមសិក្សាពោធិ៍ធំមួយខ្នងមានបួនបន្ទប់ ក្រោមការជួយឧបត្ថម្ភពីលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅខេត្តស្វាយរៀង នាថ្ងៃទី២ ខែមីនា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំជាមួយនឹងអាជ្ញាធរស្រុក ស្ដីពីការការពារសន្តិសុខ ការងារបម្រើប្រជាពលរដ្ឋនៅមូលដ្ឋាន និងត្រៀមយុទ្ធនាការរៀបចំដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតឃុំសង្កាត់ នាពេលខាងមុខ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាខេត្ត ដើម្បីផ្សព្វផ្សាយរបាយការណ៍ស្ដីពី លទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ នៅសាលប្រជុំធំសាលាខេត្ត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២។



-ចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្ត ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ស្រុកអូររាំងឪ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំស្រុក មន្ត្រីអង្គភាពការិយាល័យជុំវិញស្រុក និងអាជ្ញាធរឃុំ ភូមិ របស់ស្រុកអូររាំងឪ ចំនួន១៤៧នាក់ នៅសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ភូមិ គ្រូបង្រៀន ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ព្រមទាំងនាំយកអំណោយមួយចំនួនជូនដល់សមាជិកនៃអង្គពិធីរួមមាន៖ ភួយ៣០ អាល់កុល ដែលលាងដៃ និងថវិកាមួយចំនួន នៅឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព លោក **ជា ចំរើន** ដែលបានទទួលមរណភាព ដោយគ្រោះថ្នាក់ចរាចរណ៍ នៅភូមិសួងលិច ក្រុងសួង ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីជួបសំណេះសំណាលជាមួយនឹងនិវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនចំនួន ២២០នាក់ ក្រោមអធិបតីភាពឯកឧត្តម **អ៊ាង សុផល្លែត** រដ្ឋលេខាធិការក្រសួងបរិស្ថាន នៅសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងយុវជនទូទាំងស្រុកអូររាំងឪ ចំនួន១៣៤នាក់ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ាង សុផល្លែត** រដ្ឋលេខាធិការក្រសួងបរិស្ថាន នៅសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

❈នាថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជុំ ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំកណ្ដុរ ស្រុកបទុមសាគរ ខេត្តកោះកុង។





❈នាថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២២ឯកឧត្តម **ឌឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ច្រឹង គីមស្រាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ម៉ាស៊ីនអុកស៊ីហ្សែនចំនួន២គ្រឿង ម៉ាស៊ីនវាស់កំដៅចំនួន៦គ្រឿង ម៉ាស់ចំនួន៣កេសធំ និងឧបករណ៍ Rapitest ចំនួន២កេសធំ ប្រគល់ជូនលោក **ឌឹម ទិត្យ** ប្រធានមណ្ឌលសុខភាព ឃុំកោះសូទិន ព្រមទាំងជួបសំណេះសំណាលជាមួយនឹងលោក **ហេង សាន** ប្រធាន ស.ស.យ.ក. ឃុំ នៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមួយគ្រួសារ ព្រមទាំងប្រគល់ផ្ទះចំនួន១ខ្នង និងអំណោយរួមមាន៖ អង្ករចំនួន២៥គីឡូក្រាម មី១កេស ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ និងថវិកាមួយចំនួនផងដែរ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងគណៈអ៊ីម៉ាំខេត្ត ក្រុង ស្រុក ព្រមទាំងសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំ និងប្រពលរដ្ឋខ្មែរឥស្លាមក្នុងខេត្តកំពត សរុបជាង៥០០នាក់ នៅទីស្នាក់ការគណៈអ៊ីម៉ាំ ភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃពុធ ទី២ ខែមីនា ឆ្នាំ ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង និងភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ចុះផ្តល់កម្រាលព្រំជូនគណៈកម្មការវិហារទុកសម្រាប់ប្រើប្រាស់ថ្វាយបង្គំក្នុងព្រះវិហារ ដែលជាអំណោយសប្បុរសជនប្រទេសសិង្ហបុរី នៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅភូមិព្រៃធំ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប និងស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់កណ្តាល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំឥស្លាមខេត្តកំពត ខេត្តកែប ក្រោមអធិបតីភាព ឯកឧត្តមឧកញ៉ាបណ្ឌិត **អូស្មាន ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស នៅសាលប្រជុំគណៈអ៊ីម៉ាំ នៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយចុះចែកជូនប្រជាពលរដ្ឋចំនួន៤០គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបានអង្ករចំនួន២០គីឡូក្រាម មី ប្រេងឆា ទឹកត្រី និងតែ នៅសាលាស្រុកអង្គរជ័យ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។

❈ឯកឧត្តម **ញ៉ែវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំពុទ្ធបរិស័ទនាំយកភេសជ្ជៈ និងថវិកាបច្ច័យបួនមួយចំនួន ប្រគេនព្រះសង្ឃគង់នៅវត្តសន្ទ្រែមានជ័យ ក្នុងឱកាសពិធីចម្រើនព្រះបរិត្តសម្ពោធឧបដ្ឋានសាលាមួយខ្នង ដែលទើបនឹងសាងសង់រួច នៅឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបសំណេះសំណាលប្រធានភូមិចំនួន២ភូមិ គឺភូមិអូរព្រាល និងភូមិវាល នៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។

-ជួបសំណេះសំណាលប្រធានភូមិព្រែក១ ចំណុចវាលនិទ្រាចំនួន១៥១គ្រួសារ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២។

-ជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវក្រាលគ្រួសក្រហមមួយខ្សែ ដែលមានប្រវែង២៦,៥០គីឡូម៉ែត្រ រួមទាំងស្ពានឆ្លងស្ទឹងមួយប្រវែង៥៣ម៉ែត្រ ស្ពានខ្លីៗពី ៧ ទៅ១៥ម៉ែត្រចំនួន៥កន្លែង លូភ្លោះកាត់ថ្នល់១០កន្លែង ចាប់ពីស្ពានអន្លង់គល់រហូតដល់វត្តវាំងខ្វារ នៃឃុំសន្ទ្រែ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ព្រមទាំងសំណេះសំណាលជាមួយនឹងប្រធានភូមិក្បែត្របូរី ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។




❈នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលសន្និសីទសណ្ឋាគារសុខា ខេត្តសៀមរាប។

❈នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រធានភូមិ សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ នៅសាលឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។

❈នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្លក្រាម និងបេក្ខជនឈរឈ្មោះបោះឆ្នោតចំនួន២៤រូប ព្រមទាំងឧបត្ថម្ភក្នុងម្នាក់ៗ សារុង១ និង



ថវិកាមួយចំនួន ស្ថិតនៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

❋លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្ម-ការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៨១ សរុបចំនួន១៥១ នាក់ ដើម្បីអបអរសាទរទិវានារីអន្តរជាតិ៨មីនា ឆ្នាំ២០២២ ព្រមទាំងចែកអំណោយក្នុងម្នាក់ៗទទួលបានសំពត់ស៊ឹងខ្មែរ១សំពត់ ថ្នាំលាបសក់១ដប ខ្ទីទឹកឃ្មុំ១កញ្ចប់ និងថវិកាមួយចំនួន នៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នារសៀលថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់រង្វាន់ជូនដល់សិស្សា-នុសិស្សដែលបានប្រឡងជាប់និទ្ទេស (A) ក្នុងឆ្នាំសិក្សា២០២១កន្លងទៅ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិ នៅខេត្តកំពង់ធំ នារសៀលថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីក្រុងពលីសម្ពោធសមិទ្ធផលនានា និងស្រោចស្រពព្រះសុគន្ធវារីព្រះគ្រូរតនវិសុទ្ធិញាណ



**ហឿន សុជាតិ** បរិសុទ្ធសីលោ ឡើងជាព្រះគ្រូចៅអធិការវត្តគោកទិល (ហៅវត្តធម្មនាថ) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិ ស្ថិតនៅវត្តធម្មនាថ ភូមិធម្មនាថ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងកម្មវិធីកាត់ខ្សែបូសម្ពោធសាលា-ពុទ្ធិកសិក្សា ក្រោមអធិបតីភាពឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិ ស្ថិតនៅវត្តធម្មនាថ ភូមិធម្មនាថ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីសម្ពោធឆ្លងមហាកុដិ សាលាពុទ្ធិក (សាលាបាលី) និងសមិទ្ធផលនានានៅវត្តសានគរ ព្រមទាំងចូលបច្ច័យមួយចំនួនសម្រាប់កសាង និងឧបត្ថម្ភសម្ភាររួមមាន៖ ក្រណាត់-សចំនួន៥០ដុំ សារុងចំនួន២២០ និងថវិកាមួយចំនួន និងចែកជូនសៀវភៅ ប៊ិច និងថវិកាមួយចំនួនជូនសិស្សានុសិស្ស នៅវត្តសានគរ ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលជាមួយនឹងអ្នកគ្រូពេទ្យ អ្នកគ្រូបង្រៀន និងសិស្សានុសិស្សចំនួន១៣១នាក់ នៅសាលាខេត្តកំពង់ធំ នារសៀលថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

❋នាថ្ងៃទី៦ ខែមីនា ឆ្នាំ ២០២២ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលសកម្មភាពការងារ និងការអនុវត្តផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងលើកទិសដៅអនុវត្តបន្ត និងក្នុងឱកាសអបអរសាទរខួបលើកទី១១១ ទិវា៨មីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❋ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមៈ



-ពិធីបុណ្យទេសនាមហាជាតក ដែលជាបុណ្យប្រពៃណីព្រះពុទ្ធសាសនា និងប្រគេនបច្ច័យមួយចំនួនដល់ព្រះចៅអធិការ ចំនួន៣វត្តទៀតគឺៈ វត្តគោកខ្ពស់ វត្តប្រាសាទ និងវត្តនគរភាស សម្រាប់ចូលរួមកសាងក្នុងទីអារាមផងដែរ ស្ថិតនៅវត្តព្រៃដង្ហើម ឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។

-ពិធីបញ្ចុះបឋមសិលាសាងសង់ស្តូបវិមានអនុស្សាវរីយឈ្នះឈ្នះ អ្នកចូលរួមសរុប ចំនួន១.៥០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ



នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។



-សំណេះសំណាល និងសួរសុខទុក្ខគ្រួសារយុទ្ធជនដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់រលំផ្ទះមួយខ្នង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន ដើម្បីរួមចំណែកសង់ផ្ទះថ្មីឡើងវិញ នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នារសៀលថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **អ៊ឹម លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញៈ



-សំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សា៥ឃុំ សរុបចំនួន៦៨រូប ដើម្បីឈ្វេងយល់អំពីការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈ ការប្រមូលផលស្រូវប្រាំង ជីវភាពរស់នៅប្រចាំថ្ងៃ និងផែនការឆ្ពោះទៅកាន់ការបោះឆ្នោតឃុំ សង្កាត់ ដែលនឹងប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភ សារុង ក្រមា នៅសាលប្រជុំសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលយុវជនដែលមានអាយុ១៨ឆ្នាំ មានឈ្មោះក្នុងបញ្ជី គ.ជ.ប សរុបចំនួន៨៨

នាក់ (ស្រី៣៩នាក់) ព្រមទាំងឧបត្ថម្ភ សារុង ក្រមា និង ថវិកាមួយចំនួន នៅស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ឆេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលលោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៃវិទ្យាល័យជាស៊ីម អង្គរជ័យ នៅក្នុងស្រុកអង្គរជ័យ ខេត្តកំពត នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្ដីពីច្បាប់ បទបញ្ញា នីតិវិធីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅខេត្តកែប នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខ និងនាំយកអំណោយជាទឹកបរិសុទ្ធ ចំណីអាហារ និងថវិកាទៅឧបត្ថម្ភជូនសមាជិកក្រុមប្រឹក្សាស្រុក អភិបាលរងស្រុក និងមន្ត្រីសាលាស្រុកដំណាក់ចង្អើរ ដែលបានឆ្លងជំងឺកូវីដ-១៩ ប្រភេទអូមីក្រុង កំពុងសម្រាកព្យាបាលនៅតាមគេហដ្ឋាន ស្ថិតនៅក្នុងភូមិអន្លង់ស ឃុំពងទឹក និងភូមិទួលស្រង៉ា និងភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ និងភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប ព្រមទាំងនៅភូមិអង្គរជ័យទី២ ឃុំដំណាក់កន្ទួតខាងត្បូង ខេត្តកំពត នាព្រឹកថ្ងៃទី៤ និងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីសម្ពោធទីស្នាក់ការ សមាគមរាជសីហ៍សាខាខេត្តកែប នៅក្នុងភូមិកែប សង្កាត់កែប ក្រុង



កែប ខេត្តកែប នារសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីប្រកាសតែងតាំងបន្ថែមថ្នាក់ដឹកនាំសាខា ប្រកាសទទួលស្គាល់បន្ថែមសមាជិក សមាជិកាសាខា និងប្រកាសបង្កើតអនុសាខា ចំណុះសមាគមរាជសីហ៍ សាខាខេត្តកំពត នៅវិទ្យាស្ថានតេជោសែន ភូមិភាគកំពត ស្ថិតនៅក្នុងក្រុងកំពត ខេត្តកំពត នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។



-ដឹកនាំសមាគមរាជសីហ៍ចុះសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយជាស្បៀងអាហាររួមមាន៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ប៊ីចេង និងថវិកាមួយចំនួនជូនដល់គ្រួសារខ្មែរឥស្លាមក្រីក្រចំនួន២៥គ្រួសារ នៅភូមិតាអង្គ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធ ដើម្បីសួរសុខទុក្ខ និងឈ្វេងយល់អំពីបញ្ហាប្រឈមផ្សេងៗ ជាពិសេសជំងឺកូវីដ-

១៩ ប្រភេទថ្មី នៅក្នុងភូមិចំនួន៩ គឺភូមិឈូកស ភូមិព្រៃ-ទំនប់ ភូមិសំរោង ភូមិស្វាយសុខុម ភូមិសុវណ្ណមាលា ភូមិបុសឫស្សី ភូមិតានី ភូមិរើលលើ ភូមិរើលក្រោម នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែកុម្ភៈ និងពីថ្ងៃទី៣ ដល់ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានា និងសាលាឆាន់ក្នុងវត្តស្ទឹងតូច នៅភូមិកក់ ឃុំបឹងតូច ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំរៀបចំកម្មវិធីបុណ្យឆ្លងសមិទ្ធផលនានា នៅក្នុងវត្តរើលលើ នៅភូមិរើលលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងនាំយកសម្ភារជាឯកសណ្ឋាន និងថវិកាមួយចំនួនជូនប្រជាការពារនៅភូមិតានី ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធឆ្លងព្រះវិហារ និងសមិទ្ធផលនានាក្នុងវត្តរើល នៅភូមិរើលក្រោម ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២។

-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមា ពុទ្ធាភិសេកឆ្លងព្រះវិហារ និងសមិទ្ធផលនានាក្នុងវត្តដូនដោកលិច នៅភូមិដូនដោកលិច ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋក្រីក្រ ក្រ១ និងក្រ២ នៅឃុំដូនតី ស្រុកពញា-ក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃ២០ ខែមីនា ឆ្នាំ២០២២។

❈នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ញៀម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំស្រែឫស្សី នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈ-កម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកអង្ករ៤បាវ និងបច្ច័យមួយចំនួន ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសីយ៍ និងវត្តព្រះឥន្ទកោសាស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម និងបន្តនាំយកផ្លែឈើចំនួន៣៥គីឡូក្រាម ទៅប្រគេនព្រះសង្ឃគង់នៅវត្តចំនួន៥ផ្សេងទៀត នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួនឧបត្ថម្ភដល់អាជ្ញាធរស្រុកប្រា-សាទបាគង ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ស្ថិតនៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។

-រាប់បាត្រ និងប្រគេនបច្ច័យដល់ព្រះសង្ឃចំនួន១០៩អង្គ នៅវត្តអង្គខាងត្បូង ខេត្តសៀមរាប នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។

-នាំយកបច្ច័យមួយចំនួន ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តចំនួន២ គឺវត្តព្រះឥន្ទកោសីយ៍ ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប និងវត្តគោកតាឡុន នៅភូមិអញ្ចាញ សង្កាត់នគរធំ ស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២៕

## សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញបំពេញបេសកកម្មក្រៅប្រទេស



❈នាថ្ងៃទី១៩ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាទៅចូលរួមក្នុងមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤ (IPU-144) និងកិច្ចប្រជុំសមាគមអគ្គលេខា-ធិការសភាពិភពលោក (ASGP) នៅនូហ្សាឌូ កោះបាលី សាធារណរដ្ឋឥណ្ឌូណេស៊ី៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❋នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំ ដើម្បីត្រៀមចូលរួមក្នុងមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤ (IPU-144) នៅសាលបន្ទាយស្រី វិមានរដ្ឋសភា។

❋ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ម៉ែន ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួម៖



-ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិដំណាក់កាលទី២(២០២១-២០៣០) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

-ពិធីបិទការប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅសណ្ឋាគារសុខា រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។





❋នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីទទួលគ្រឿងឥស្សរិយយស (Insignes de Chevalier des Palmes accadémiques) របស់កញ្ញា **គង់ សុមនី** ដែលត្រូវបានបំពាក់ដោយឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា នៅនិវេសនដ្ឋាននៃស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

❋ឯកឧត្តម **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីកាត់ឫសសីមាព្រះវិហារវត្តស្ទឹងឆាយ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅភូមិស្ទឹងឆាយ ឃុំស្ទឹងឆាយ ខេត្តព្រះសីហនុ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

ក្រសួងមហាផ្ទៃ នៅខេត្តព្រះសីហនុ នាថ្ងៃទី៩ ខែមីនា ឆ្នាំ ២០២២។

-ទទួលជួបជាមួយនឹងលោក Victor Come ជនជាតិអ៊ុយក្រែនមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីបច្ចេកទេសដាំផ្កាចិញ្ចឹមឃ្មុំ នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។

-ទទួលជួបជាមួយនឹងក្រុមអ្នកវិនិយោគទុនមកពីប្រទេសជប៉ុនចំនួន២រូប ដែលចង់បោះទុនវិនិយោគសាងសង់ភូមិឋានបែបបុរាណជប៉ុន នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីខួបអនុស្សាវរីយគម្រប់៣០ឆ្នាំ ថ្ងៃបំពេញបេសកកម្មជាប្រវត្តិសាស្ត្រឥស្សរជន១២រូប របស់វរសេនាតូចលេខ២៤៦ អតីតយោធាក្រុងភ្នំពេញ ដែលបានមកបំពេញភារកិច្ចការពារសន្តិសុខសុវត្ថិភាពជូនសម្តេចទាំងទ្វេ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង និងមេបញ្ជាការកងទ័ពជើងគោក នៅទីបញ្ជាការដ្ឋានអង្គរក្សខេត្តកណ្តាល នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២។



❋នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ លោកជំទាវ **ទី ចូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអនុញ្ញាតឱ្យប្រតិភូក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិផារ៉ាហ្គុន PARAGON Inter national School ដឹកនាំដោយលោក Damir Musaev នាយកប្រតិបត្តិ នៃកម្មវិធីសាលាចូលជួបសម្តែងការគួរសម និងជូនពរក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។



❋នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ សាលាបឋមសិក្សា និងវិទ្យាល័យតេជោសែនត្បូងឃ្មុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីអបអរសាទរខួបលើកទី១១១ ទិវាអន្តរជាតិនារី ៨មីនា ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅវិទ្យាស្ថានជាតិអប់រំ នាព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។

-ផ្តល់បទសម្ភាសដល់ស្ថានីយទូរទស្សន៍ និងវិទ្យុអប្សរា ដើម្បីផលិតវីដេអូឯកសារស្តីពី «ទិវាអន្តរជាតិនារី ៨មីនា» នៅសាលប្រជុំគណៈកម្មការទី៨ ព្រឹទ្ធសភា នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។



-ចូលរួមពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០២២ ខួបលើកទី១១១ របស់សមាគមនារី និងក្រុមការងារចលនាស្ត្រី ខេត្តកណ្ដាល ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត" ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅខេត្តកណ្ដាល នាព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការភូមិកុមារ SOS ព្រៃវែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអគារលេខ១៨៨ ផ្លូវលេខ២៧១ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

❃ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញៈ



-ចូលរួមពិធីបុណ្យពុទ្ធាភិសេកសាមញ្ញាតិភិសេកឆ្លងព្រះចេតិយ និងអភិសេករូបបដិមាឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធលោកជំទាវ **អ៊ូច សំអាត** ភរិយាឯកឧត្តម **ស្រី បេន** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងឧទ្ទិសកុសលជូនដល់ជីដូន ជីតា ញាតកាទាំងប្រាំពីរសន្តានដែលបានចែកឋានទៅកាន់លោកខាងមុខ នៅភូមិល្វេ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបូជាសពឧបាសិកា **សីលវត្តី ជិន យេន** ម្ដាយបង្កើតរបស់លោកជំទាវ **គង់ សៅរ៍ឆន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងជាសមាជិកាក្រុមសមាជិកាព្រឹទ្ធសភា ដែលបានទទួលមរណភាពកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ក្នុងជន្មាយុ ៩០ឆ្នាំ ដោយជរាពាធ នៅស្រុកកំពង់ត្រាច ខេត្តកំពត នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២។




❃នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព នាយឧត្តមសេនីយ៍ **សុខ សារឿន** រដ្ឋលេខាធិការក្រសួងការពារជាតិ នៅបញ្ជាការដ្ឋានកងអង្គរក្ស សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។



❃នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានទទួលជួបពិភាក្សាការងារជាមួយនឹងឯកឧត្តមបណ្ឌិត **ទី ថានី** អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា។

❈នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតលើកទី១៤៤ របស់សហភាពអន្តរសភា IPU ដែលនឹងប្រារព្ធធ្វើចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី ក្រោមអធិបតីភាពឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈប្រតិភូសភាកម្ពុជាចូលរួមមហាសន្និបាតលើកទី១៤៤ របស់សហភាពអន្តរសភា (IPU) និងជាប្រធានគណៈកម្មការទី៥រដ្ឋសភា នៅសាលប្រជុំបន្ទាយស្រី វិមានរដ្ឋសភា។



❈នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការសាលារៀនអាល់អាហ្វាហ្វរបស់សមាគមប្រភពល្អប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ នៅភូមិកំពង់កណ្ដាល ឃុំជុំគៀល ស្រុកទឹកឈូ ខេត្តកំពត។

❈ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិសាអាហារសាមគ្គីដែលរៀបចំឡើងដោយស្ថានទូតគុយវ៉ែតប្រចាំកម្ពុជា ដើម្បីអបអរសាទរទទួលស្វាគមន៍ ឯកឧត្តម Saleh Mohamed Ahmed Alsaqri ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូម៉ង់ ដែលទើបត្រូវបានតែងតាំងជាឯកអគ្គរាជទូតថ្មីប្រចាំកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានកុងស៊ុលគុយវ៉ែតប្រចាំកម្ពុជា នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីបើកការប្រកួតបាល់ទាត់ដណ្ដើមពានរង្វាន់ QAENAT SAFFRON រដូវកាលទី១ ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីក្រុមហ៊ុន Ggo Global Co.,LTD នៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីបិទការប្រកួតបាល់ទាត់ដណ្ដើមពានរង្វាន់ QAENAT SAFFRON រដូវកាលទី១ ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីក្រុមហ៊ុន Ggo Global Co.,LTD នៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២។



❈នារសៀលថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញផ្ដល់កិច្ចសម្ភាសដល់អង្គការខាណា (KHANA) ក្នុងកម្មវិធីជជែកពិភាក្សាតុមូលសម្រាប់ចាក់ផ្សាយនៅលើកញ្ចក់ទូរទស្សន៍ ស្ដីពី “កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្រោយការរាតត្បាត នៃជំងឺកូវីដ-១៩ ដើម្បីឆ្ពោះទៅសម្រេចបានគោលដៅនៃកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្ដីពីជំងឺរបេង ឆ្នាំ២០២៣” នៅ Blue Media Cambodia ស្ថិតនៅសង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងកំណត់ទិសដៅការងារខែមីនា ឆ្នាំ២០២២



*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍នាពេលនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែកុម្ភៈថា ក្នុងបរិបទប្រែប្រួលថ្មីនារយៈពេលចុងក្រោយដែលការគំរាមកំហែងដោយជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងកើតមានឡើងកាន់តែច្រើន ហើយដើម្បីឆ្លើយតបនឹងស្ថានភាពនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក៏បានបង្កើនការយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ។ ទន្ទឹមនឹងនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្ដល់សេវាតាមគន្លងថ្មីជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្ដែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន។ ជាពិសេសក្នុងបរិបទ នៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានផ្ដោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្ដល់សេវាជូនគណៈកម្មការជំនាញទាំង ១០ ចុះបំពេញបេសកកម្មជួបសវនាការការងារជាមួយនឹងក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរ





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ*



*ទិដ្ឋភាពកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ២០២២*

គ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយនឹងជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ ដែលកំពុងជួបការលំបាក នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា។

ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូជាតិ និងអន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តយកចិត្តទុកដាក់ដល់មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានក្រសួងសុខាភិបាល ឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ ឱ្យបានល្អប្រសើរ។

សម្រាប់ខែមីនាខាងមុខ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានកំណត់ឱ្យគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្តផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥ របស់ព្រឹទ្ធសភា ប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញបិទវគ្គបច្ចេកទេសក្នុងការតាក់តែងឯកសារ សម្រាប់គាំទ្រមហាសន្និបាតអាយប៉ាលើកទី៤៣



*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នារសៀលថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសក្នុងការតាក់តែងឯកសារសម្រាប់គាំទ្រមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសភាអាស៊ី ក្រោមក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងមជ្ឈមណ្ឌលសភាអាស៊ី តាមប្រព័ន្ធនិម្មិត (Zoom) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

បន្ទាប់ពីបានស្តាប់របាយការណ៍វាយតម្លៃរបស់គ្រូឧទ្ទេសនាម និងរបាយការណ៍សង្ខេបរបស់តំណាងសិក្ខាកាម ព្រមទាំងចំណាប់អារម្មណ៍របស់លោក **ដាវ៉ារិទ្ធ គឹមយាត** នាយកប្រតិបត្តិមជ្ឈមណ្ឌលសភាអាស៊ី រួចមក ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានវាយតម្លៃខ្ពស់ចំពោះសិក្ខាកាមមកពីព្រឹទ្ធសភា រដ្ឋសភា ដែលបានទទួលនូវពុទ្ធិថ្មី និងបានក្រេបជញ្ជក់យកនូវបច្ចេកទេសសំខាន់ៗក្នុងការតាក់តែងខ្លឹមសារឯកសារឱ្យកាន់តែស៊ីជម្រៅគ្រប់ជ្រុងជ្រោយ ប្រទាក់ក្រឡាទៅនឹងមូលបទ នៃមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជានឹងធ្វើជាប្រធានរៀបចំដឹកនាំកិច្ចប្រជុំនៅឆ្នាំនេះ។ នេះគឺជាឱកាសដ៏ល្អមួយសម្រាប់មន្ត្រីសភា ក្នុងការបំប៉នសមត្ថភាពបន្ថែមលើជំនាញតាក់តែងឯកសារខ្លឹមសារសំខាន់ៗរបស់មហាសន្និបាត រួមមាន សេចក្តីថ្លែងការណ៍ បទអន្តរាគមន៍ សុន្ទរកថា។ល។ ដែលទាមទារឱ្យមាននូវធនធានផ្ទាល់ខ្លួនប្រកបដោយសមត្ថភាពពិតប្រាកដ ធ្វើជាសេនាធិការដល់ក្រុមសមាជិកសភា ដែលត្រូវចាត់ឱ្យចូលរួមក្នុងវេទិកា ឬកិច្ចប្រជុំតំបន់ និងអន្តរជាតិនានាដូចជាមហាសន្និបាតអាយប៉ាលើកទី៤៣ នេះជាដើម។




*ទិដ្ឋភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធនិម្មិត*





*លោក ដារ៉ារិទ្ធ គឹមយាត និងលោក ឈាង វណ្ណារិទ្ធិ អញ្ជើញមានចំណាប់អារម្មណ៍*

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា លទ្ធផលទាំងនេះ គឺបានមកពីការដែលមានកិច្ចសហការល្អជាមួយនឹងវិទ្យាស្ថានសភាកម្ពុជា ដែលថ្មីៗនេះបានវិវឌ្ឍន៍ទៅជាមជ្ឈមណ្ឌលសភាអាស៊ី ក្នុងការពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវការចាំបាច់ជានិច្ចនូវកិច្ចសហប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌលសភាអាស៊ី។ ដូច្នេះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសង្ឃឹមថា មជ្ឈមណ្ឌលសភាអាស៊ីនឹងនៅតែបន្តរិះរកមធ្យោបាយ ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីសភាកម្ពុជា។

សូមជម្រាបថា វគ្គបណ្តុះបណ្តាលនេះសិក្សាចាប់ពីថ្ងៃទី២១ ខែមករា ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ មានសិក្ខាកាមចូលរួមសរុបចំនួន១៧នាក់ មកពីព្រឹទ្ធសភាចំនួន៦នាក់ និងមកពីរដ្ឋសភាចំនួន១១នាក់។

(អត្ថបទ៖ គឹម សិទ្ធី និងរូបភាព៖ គង់ យ៉ារីន)




*ឯកឧត្តម អ៊ុំ សារិទ្ធ ថ្លែងសុន្ទរកថាក្នុងពិធីបិទវគ្គ*



*ទិដ្ឋភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធនិម្មិត*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញបំពេញបេសកកម្មការងារនៅប្រទេសបារាំង





*ឯកឧត្តម អ៊ុំ សារឹទ្ធ បំពេញបេសកកម្មការងារនៅប្រទេសបារាំង*

កាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា បានអញ្ជើញបំពេញបេសកកម្មការងារនៅសាធារណរដ្ឋបារាំង។ ក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងភាគីពាក់ព័ន្ធ ដូចជា៖

**១-នៅព្រឹទ្ធសភាបារាំង**

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា បានជួបជាមួយនឹងឯកឧត្តម Eric Tavernier អគ្គលេខាធិការព្រឹទ្ធសភាបារាំង ដើម្បីបញ្ជាក់ឡើងវិញនូវបំណងប្រាថ្នារួម ដើម្បីបង្កើនទំនាក់ទំនងរវាងព្រឹទ្ធសភាទាំងពីរ តាមរយៈការផ្លាស់ប្ដូរគណៈប្រតិភូទៅវិញទៅមក និងការជួយបណ្ដុះ-បណ្ដាលធនធានមនុស្ស តាមរយៈយន្តការទ្វេភាគី និងពហុភាគីក្នុងក្របខ័ណ្ឌ AIPA។

**២-នៅរដ្ឋសភាបារាំង**

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា បានជួបជាមួយនឹងលោកស្រី MARIE VIGOUROUX ទីប្រឹក្សាទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរសភានៃរដ្ឋសភាបារាំង ដោយទទួលបានការគាំទ្រ និងសហប្រតិបត្តិការដូចនៅព្រឹទ្ធសភាបារាំងដែរ ទាំងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។ រដ្ឋសភាបារាំងត្រៀមចុះអនុស្សរណៈជាថ្មីនៅក្រោយការបោះឆ្នោតនាឆ្នាំ២០២២នេះ។ ក្នុងអន្តរកាលនេះ ភាគីរដ្ឋសភាបារាំងអាចចូលរួមសហការបានលើគ្រប់កម្មវិធីចំពោះមុខ។

**៣-នៅអគ្គលេខាធិការដ្ឋាន APF**

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជួបជាមួយនឹងឯកឧត្តម DAMIEN CESSELIN អគ្គលេខាធិការរដ្ឋបាលថ្មី APF ដោយមានការចូលរួមពីលោកជំទាវ NGUYEN TUNG VAN អគ្គលេខាធិការ AIPA។ ភាគីបារាំងសម្ដែងបំណងសហប្រតិបត្តិការ ដើម្បីចូលរួមចំណែកបណ្ដុះ-បណ្ដាលធនធានមនុស្សក្នុងក្របខ័ណ្ឌ AIPA ជាពិសេសសម្រាប់ប្រទេសហ្វ្រង់កូហ្វូនីទាំង៣៖ កម្ពុជា វៀតណាម ឡាវ និងមន្ត្រីហ្វ្រង់កូហ្វូនីតំបន់។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជួបជាមួយនឹងលោកស្រី MIREILLE EZA ទីប្រឹក្សាតំបន់អាស៊ីប៉ាស៊ីហ្វិកទទួលបន្ទុកសហប្រតិបត្តិការជាមួយនឹងកម្ពុជា រួមទាំងពិសាអាហារថ្ងៃត្រង់ដើម្បីពិភាក្សាការងារជាមួយនឹងឯក-ឧត្តមអគ្គលេខាធិការរដ្ឋបាលថ្មី APF អំពីសហប្រតិបត្តិការរវាង APF និងសភាកម្ពុជា ក្នុងឆ្នាំ២០២២។

**៤-ការងារជាមួយនឹងដៃគូនានា**

ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា បានជួបជាមួយនឹងវិទ្យាស្ថានស្រាវជ្រាវច្បាប់នៃសាកល-វិទ្យាល័យ Zurich តំណាងដោយបណ្ឌិត FELIX UHL-MANN និងវិទ្យាស្ថាន Est-West Management តំណាងដោយលោកស្រី RACHEL TRITT អនុប្រធាន ដើម្បីត្រៀមផ្ដល់ការសហការ និងធនធានស្រាវជ្រាវអំពីប្រធានបទពាក់ពន្ធ័ននឹងមហាសន្និបាត AIPA នៅកម្ពុជានាពេលខាងមុខ៕

# ឯកឧត្តម អ៊ុំ សារិទ្ធ ចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង



*ឯកឧត្តម អ៊ុំ សារិទ្ធ ចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ASGPF នៅប្រទេសសេណេហ្គាល់*

នាថ្ងៃទី៣ ដល់ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) នៅរដ្ឋសភាសេណេហ្គាល់ (Senegal) និងនៅសណ្ឋាគារ Pullman នៃប្រទេសសេណេហ្គាល់។

កិច្ចប្រជុំនោះធ្វើឡើងក្រោមអធិបតីភាព លោកជំទាវ Marie Josephine Diallo ប្រធានសមាគមអគ្គលេខាធិការនៃសភាប្រើភាសាបារាំង និងជាអគ្គលេខាធិការរដ្ឋសភាសេណេហ្គាល់ ដោយបានសម្រេចនូវខ្លឹមសារសំខាន់ៗតាមរបៀបវារៈ ដូចខាងក្រោម៖

**-ការបន្តកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ASGPF ការកំណត់កាលបរិច្ឆេទ និងទីកន្លែងនៃមហាសន្និបាត ASGPF ដែលនឹងប្រព្រឹត្តទៅនាដើមខែកញ្ញា ឆ្នាំ២០២២ នៅប្រទេសម៉ារ៉ុក។**

**-ប្រធានបទសំខាន់ៗដែលកំណត់ក្នុងរបៀបវារៈ នៃមហាសន្និបាត ASGPF នៅប្រទេសម៉ារ៉ុក។**

**-ការប្រមូលវិភាគទានចំពោះសាមាជិកណាដែលមិនទាន់បង់។**

**-ការបោះឆ្នោតជ្រើសរើសសមាជិកថ្មីនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ASGPF ដែលត្រូវបែងចែកតាមភូមិសាស្ត្រតំបន់។**

ព្រមជាមួយគ្នានោះ អង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ASGPF បានស្នើឱ្យកម្ពុជាបន្តស្ថិតនៅជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ASGPF សម្រាប់អាណត្តិថ្មី និងស្នើឱ្យកម្ពុជាធ្វើបទបង្ហាញអំពីបទពិសោធន៍អំពីការកសាងមជ្ឈមណ្ឌលសភាអាស៊ីរបស់កម្ពុជា ដែលទទួលបានជោគជ័យ។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី ការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងស្ដាប់ការធ្វើសេចក្ដីរាយការណ៍របស់អាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ស្ដីពី លទ្ធផលសម្រេចបាន បញ្ហាប្រឈម និងសំណូមពរនានា។



❈នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោក Olivier Rodien ប្រធានសមាគមបេសកកម្ម កម្មសិក្សាអាស៊ី មានមូលដ្ឋាននៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំគណៈកម្មការពិនិត្យវាយតម្លៃដំឡើងថ្នាក់បៀវត្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិភាក្សាស្ដីអំពី លក្ខណសម្បត្តិ និងពិនិត្យ វាយតម្លៃសមត្ថភាពមន្ត្រីរាជការ ដែលជាបេក្ខជនត្រូវវាយតម្លៃដំឡើងថ្នាក់បៀវត្ស តាមវេនអតីតភាព និងវេនជ្រើសរើសសម្រាប់ឆ្នាំ២០២២ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នៅរសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ច័ន្ទ ផល្លី** ភរិយារបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ឈិន ច័ន្ទពណ៌** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ នៅផ្ទះលេខ៨១-៨៣ ផ្លូវ១៦០ ភូមិ៨ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នៅព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ភូ យ៉ាន** នៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។



❈នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ជូនសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យករណីមន្ត្រីទៅសិក្សាថ្នាក់បរិញ្ញាបត្រ នៅសហរដ្ឋអាមេរិក ដោយមានការអញ្ជើញចូលរួមពីអគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ អគ្គាធិការ និងថ្នាក់ដឹកនាំនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី "កិច្ចការសភា (ជំហានទី៤)" ក្រោមអធិបតីភាពឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា នៅសាលសិក្ខាសាលខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ **អ៊ូ សាន** ចំនួន១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក) ជូនកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា៕



